# ប្រទេសកម្ពុជា៖ បោះជំហានឆ្ពោះទៅ
# បង្កើតរបបសន្តិសុខសង្គម ដែលមាន
# លក្ខណៈកាន់តែប្រសើរជាងមុន







## រោងចក្រកាន់តែប្រសើរនៅកម្ពុជា


រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

ILO
អង្គការ
ពលកម្ម
អន្តរជាតិ

# របបសន្តិសុខសង្គម ~ ទិដ្ឋភាពរួម

សេចក្តីប្រកាសជាសកលអំពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ឆ្នាំ ១៩៤៨ ចែងថា “ក្នុងនាមជាសមាជិករបស់សង្គម មនុស្សគ្រប់រូបមានសិទ្ធិទទួលបានរបបសន្តិសុខសង្គម”។[១] ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីធានាសន្តិសុខផ្នែកសេដ្ឋកិច្ច និង សុខុមាលភាពសង្គមសម្រាប់ប្រជាពលរដ្ឋរបស់ខ្លួន រដ្ឋបានបង្កើតនូវប្រព័ន្ធរបបសន្តិសុខសង្គម ដើម្បីជួយដល់អ្នកទាំងឡាយណាដែលបានជួបប្រទះនឹងផលវិបាកដោយបញ្ហាហិរញ្ញវត្ថុជាយថាហេតុ ដូចជា បញ្ហាជម្ងឺ ការបាត់បង់ប្រាក់ចំណូល គ្រោះថ្នាក់ការងារ វ័យចាស់ជរា ការស្លាប់របស់អ្នកទ្រទ្រង់ជីវភាពគ្រួសារ។

រូបភាពទី ១ បង្ហាញពីរបៀបដែលរបបសន្តិសុខសង្គមរួម ត្រូវបានផ្តល់ហិរញ្ញវត្ថុនៅតាមបណ្តាប្រទេសជាច្រើននៅជុំវិញពិភពលោកតាមរយៈការបង់វិភាគទានពីសំណាក់និយោជក និងកម្មករនិយោជិតក៏ដូចជាការបង់វិភាគរបស់រដ្ឋតាមរយៈការបង់ពន្ធ។

រូបភាពទី ១: ប្រព័ន្ធរបបសន្តិសុខសង្គមរួម




នៅតាមបណ្តាប្រទេសជាច្រើន និយោជក និយោជិត និង រដ្ឋផ្តល់វិភាគទានរួមគ្នាដើម្បីគាំទ្រផ្នែកហិរញ្ញវត្ថុដល់របបសន្តិសុខសង្គមដែលផ្តល់អត្ថប្រយោជន៍ដល់អ្នកដែលត្រូវការជំនួយ។ ប្រព័ន្ធរបបសន្តិសុខសង្គមដែលអាចដំណើរការបានល្អផ្តល់អត្ថប្រយោជន៍ដល់គ្រប់សមាជិកទាំងអស់របស់សង្គម និងឈានទៅរកការបង្កើនស្ថិរភាពសង្គម និងសេដ្ឋកិច្ច។ ប្រព័ន្ធរបបសន្តិសុខសង្គម ដែលដំណើរការបានល្អមានសារៈសំខាន់ជាពិសេសនៅក្នុងរយៈពេលកំពុងមានវិបត្តិសេដ្ឋកិច្ចដើម្បីកាត់បន្ថយផលប៉ះពាល់សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលពាក់ព័ន្ធជាមួយនឹងភាពគ្មានការងារធ្វើ ការងារដែលទទួលបានប្រាក់ខែតិច និងការកាត់បន្ថយប្រាក់ចំណូល។ ប្រព័ន្ធរបបសន្តិសុខសង្គមអាចជួយគ្រួសារដែលប្រឈមមុខនឹងផលវិបាកផ្នែកហិរញ្ញវត្ថុលើបញ្ហាជម្ងឺ (ការបាត់បង់ប្រាក់ចំណូលដោយសារតែម៉ោងធ្វើការ និងផលិតភាពត្រូវបានកាត់បន្ថយ ការចំណាយលើការថែទាំសុខភាព)។ ប្រព័ន្ធនេះផ្តល់ការការពារដល់កម្មករនិយោជិតនៅក្នុងករណីដែលពួកគេបាត់បង់សមត្ថភាពធ្វើការងារ គ្រោះថ្នាក់ការងារ សម្រាកលំហែមាតុភាព ឬចូលនិវត្តន៍។ ផលប្រយោជន៍ជាច្រើនដែលគ្រួសារត្រូវទទួលបាន គឺការជួយកាត់បន្ថយនូវបន្ទុកគ្រួសារដែលមានកូនៗ និងផ្តល់ឱ្យនូវការអភិវឌ្ឍធនធានសង្គមក្នុងរយៈពេលវែង។ និយោជកក៏ទទួលបានអត្ថប្រយោជន៍ផងដែរពីរបបសន្តិសុខសង្គមតាមរយៈការកើនឡើងនូវផលិតភាពរបស់កម្លាំងពលកម្ម និងសន្តិភាពនៅក្នុងសង្គម។ ប្រព័ន្ធរបបសន្តិសុខសង្គមក៏ផ្តល់អត្ថប្រយោជន៍ដល់ប្រទេសនានាផងដែរ ដែលត្រូវបានបង្កើតឡើងតាមរយៈការបង្កើនស្ថិរភាពសន្តិសុខ ការស្រុះស្រួលគ្នាក្នុងសង្គម ការកាត់បន្ថយវិសមភាព និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

បើទោះបីជាមានការទទួលស្គាល់ទូលំទូលាយអំពីសារៈសំខាន់នៃរបបសន្តិសុខសង្គមក៏ដោយ ក៏នៅក្នុងពិភពលោកទាំងមូលមានមនុស្សតែម្នាក់ក្នុងចំណោមប្រាំនាក់ប៉ុណ្ណោះដែលទទួលបានរបបសន្តិសុខសង្គមគ្រប់គ្រាន់។ មានប្រទេសកំពុងអភិវឌ្ឍតិចតួចដែលមានលទ្ធភាពផ្តល់កិច្ចគាំពារសង្គមជាមូលដ្ឋានដល់ប្រជាពលរដ្ឋរបស់ខ្លួន។ នៅក្នុងឆ្នាំ ២០០៣ អង្គការពលកម្មអន្តរជាតិ (ILO) ចាត់ទុកកិច្ចគាំពារសង្គមជាអាទិភាពខ្ពស់បំផុតមួយ ហើយបានប្រកាសចាប់ផ្តើមយុទ្ធនាការសកលអំពី *របបសន្តិសុខសង្គម និងការគ្របដណ្តប់ សម្រាប់ទាំងអស់គ្នា*ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយគម្លាតទាំងនេះ។[២] កាលពីពេលថ្មីៗនេះ អង្គការសហប្រជាជាតិបានតែងតាំងអង្គការពលកម្មអន្តរជាតិ និង អង្គការសុខភាពពិភពលោកឱ្យធ្វើជាទីភ្នាក់ងារនាំមុខគេ ដើម្បីបង្កើតគោលការណ៍ស្តីពីកិច្ចគាំពារសង្គមជាមូលដ្ឋានមួយ ដែលមានការឯកភាពគ្នាជាលក្ខណៈអន្តរជាតិ។ ក្នុងស្មារតីដូចគ្នានេះដែរ ប្រទេសកម្ពុជាកំពុងព្យាយាមសម្រេចនូវរបៀបវារៈស្តីពីកិច្ចគាំពារសង្គមរបស់ខ្លួនយ៉ាងសកម្មដោយបានបង្កើតនូវយុទ្ធសាស្ត្រជាតិស្តីពីកិច្ចគាំពារសង្គមសម្រាប់ប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋងាយរងគ្រោះដែលជាសំអាងមួយច្បាស់លាស់ ដើម្បីឈានដល់កម្រិតគាំពារសង្គម។



[១] មាត្រាទី ២២ នៃសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស (www.un.org/en/documents/udhr/index.shtml#a22)

[២] សម្រាប់ព័ត៌មានបន្ថែម សូមមើល : www.ilo.org/public/english/protection/socsec/pol/campagne/index.htm

## របបសន្តិសុខសង្គមនៅក្នុងប្រទេសកម្ពុជា

កិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើតប្រព័ន្ធរបបសន្តិសុខសង្គមសាធារណៈនៅក្នុងប្រទេសកម្ពុជាទើបតែនឹងមានកាលពីពេលថ្មីៗនេះតែប៉ុណ្ណោះ។ នៅក្នុងខែកញ្ញា ឆ្នាំ២០០២ ប្រទេសកម្ពុជាបានអនុម័តច្បាប់ជាតិស្តីពីរបបសន្តិសុខសង្គមដំបូងរបស់ខ្លួន។ ច្បាប់នេះក៏ដូចជាអនុក្រឹត្យ និងប្រកាសនានាដែលពាក់ព័ន្ធ ចែងពីគោលការណ៍ណែនាំស្តីពីប្រព័ន្ធរបបសន្តិសុខសង្គម តម្រូវដោយច្បាប់សម្រាប់កម្មករនិយោជិតក្នុងវិស័យឯកជនដែលមានផ្នែកសំខាន់ៗ ចំនួនបី:[៣]

- ការធានារ៉ាប់រងគ្រោះថ្នាក់ការងារ (EII)
- របបធានារ៉ាប់រងសុខភាព
- របបសោធន

ជាមួយជំនួយបច្ចេកទេសពីអង្គការពលកម្មអន្តរជាតិ ប្រទេសកម្ពុជាបានចាប់ផ្តើមអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមរបស់ខ្លួន ជាមួយនឹងការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម (NSSF) នៅក្នុងឆ្នាំ២០០៧ និងការដាក់ឱ្យអនុវត្តនូវការធានារ៉ាប់គ្រោះថ្នាក់ការងារ (EII) ដែលតម្រូវដោយច្បាប់សម្រាប់កម្មករនិយោជិតក្នុងវិស័យឯកជននៅក្នុងឆ្នាំ២០០៨។ ការអនុវត្តរបបធានារ៉ាប់រងសុខភាព និងរបបសោធនគ្រោងនឹងធ្វើជាបន្តបន្ទាប់។



## បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)

ក្រោមកិច្ចសហការរវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប.ស.ស គឺជាសាខារដ្ឋបាលនៃប្រព័ន្ធរបបសន្តិសុខសង្គមដែលទើបបង្កើតឡើងនៅក្នុងប្រទេសកម្ពុជានេះ។ ស្ថាប័ននេះត្រូវបានគ្រប់គ្រង និងពិនិត្យតាមដានដោយស្ថាប័នអភិបាលត្រីភាគីមួយដែលមានសមាសភាពជាតំណាងរបស់រដ្ឋាភិបាល កម្មករនិយោជិត និងនិយោជក។ ចាប់តាំងពីបានចាប់ផ្តើមដំណើរការនៅក្នុងឆ្នាំ២០០៧ មក ប.ស.ស បានធ្វើការចុះឈ្មោះក្រុមហ៊ុន ប្រមូលវិភាគទានសមាជិក គ្រប់គ្រងការវិនិយោគដោយប្រើប្រាស់មូលនិធិដែលទទួលបាន និងផ្តល់អត្ថប្រយោជន៍ដល់កម្មករនិយោជិត និងគ្រួសាររបស់ពួកគេ។[៤]

## របបធានារ៉ាប់រងគ្រោះថ្នាក់ការងារ (EII)

របបធានារ៉ាប់រងគ្រោះថ្នាក់ការងារ គឺជារបបធានារ៉ាប់រងសង្គមដែលតម្រូវដោយច្បាប់ដែលផ្តល់ការធានារ៉ាប់រងលើគ្រោះថ្នាក់ និងជំងឺពាក់ព័ន្ធនឹងការងារដល់មនុស្សគ្រប់រូបធ្វើការងារនៅក្នុងប្រទេសកម្ពុជាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារដោយមិនគិតពីសញ្ជាតិ ពូជសាសន៍ ភេទ សាសនា ទស្សនៈនយោបាយ ឬដើមកំណើតសង្គមរបស់ពួកគេឡើយ។ ពួកគេគឺជាកម្មករនិយោជិតក្នុង វិស័យឯកជន និងសាធារណៈ (ដែលមិនស្ថិតនៅក្រោមលក្ខខន្តិកៈរួមសម្រាប់មន្ត្រីរាជការ ឬលក្ខខន្តិកៈសម្រាប់មន្ត្រីការទូត) កូនជាង និងកម្មករនិយោជិតបណ្តោះអាសន្ន។[៥]

---

[៣] រាជរដ្ឋាភិបាលកម្ពុជា ២០០២: ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ (//www.nssf.gov.kh/); អនុក្រឹត្យលេខ ១៦/០៧ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គម មាត្រាទី ៣.៥ ប្រកាសលេខ ០២២/០៨, មាត្រាទី ១។

[៤] អនុក្រឹត្យលេខ ១៦/០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម (បកប្រែក្រៅផ្លូវការដោយ CAMFEBA, www.camfeba.com/)

[៥] ច្បាប់ស្តីពីរបបសន្តិសុខសង្គម (២០០២)



របបធានារ៉ាប់រងគ្រោះថ្នាក់ការងារនេះទទួលបានថវិកាពីការចូលរួមវិភាគទានរបស់និយោជក និងឧបត្ថម្ភធនរបស់រដ្ឋ។ គ្រប់ក្រុមហ៊ុនទាំងអស់ដែលមាននិយោជិតចាប់ពី ៨ នាក់ ឡើងទៅត្រូវចុះឈ្មោះជាមួយនឹង ប.ស.ស។ អត្រាបង់វិភាគទានរបស់និយោជកចំពោះរបបធានារ៉ាប់រងគ្រោះថ្នាក់ការងារគឺ ០,៨% នៃប្រាក់ឈ្នួលប្រចាំខែមុនកាត់ពន្ធរបស់និយោជិតម្នាក់ៗ។ ប៉ុន្តែ អត្រានេះត្រូវបានកាត់បន្ថយមកនៅត្រឹម ០,៥% នៅក្នុងឆ្នាំ ២០០៩ និង ២០១០ ដោយសារតែវិស័យសម្លៀកបំពាក់ និងស្បែកជើងជួបប្រទះនឹងការលំបាកដើម្បីកាត់បន្ថយចំណាយរបស់វិស័យទាំងពីរនេះ នៅក្នុងពេលកំពុងមានការធ្លាក់ចុះសេដ្ឋកិច្ចជាសកល។[៦] អត្រា ០.៣% ដែលនៅសល់ត្រូវបានបង់ដោយរដ្ឋាភិបាល។

ការខកខានមិនបានអនុលោមទៅតាមលក្ខខណ្ឌចុះឈ្មោះ ឬបង់វិភាគទានត្រូវទទួលរងការដាក់ទោសទណ្ឌទៅតាម ច្បាប់ស្តីពីរបបសន្តិសុខសង្គម។

ការអនុវត្តរបបនេះបានចាប់ផ្តើមក្នុងទីក្រុងភ្នំពេញ ខេត្តកណ្តាល និងខេត្តកំពង់ស្ពឺ។ នៅក្នុងឆ្នាំ ២០០៩ មានជិត ១០០០ ក្រុមហ៊ុនបានចុះឈ្មោះជាមួយបេឡាជាតិនេះ ហើយមានការទាមទារសំណងជាង ២៥០០ ដែលបានដាក់សំណើមក (គិតមកត្រឹមខែមិនា ឆ្នាំ២០១០)។ មានកម្មករនិយោជិតជិត ៩០% បានចុះឈ្មោះក្នុងកំឡុងពេលធ្វើការក្នុងឆ្នាំ២០០៩ នៅក្នុងឧស្សាហកម្មកាត់ដេរ និងស្បែកជើង។ ប.ស.ស គ្រោងនឹងពង្រីកការគ្របដណ្តប់នៃរបបធានារ៉ាប់រងគ្រោះថ្នាក់ការងារទៅកាន់តំបន់ផ្សេងទៀត និងពង្រីកចំនួនក្រុមហ៊ុនដែលចុះឈ្មោះនាពេលអនាគតដ៏ខ្លីខាងមុខនេះ។[៧]

របបធានារ៉ាប់រងគ្រោះថ្នាក់ការងារត្រូវបានរៀបចំឡើងដើម្បីផ្តល់ការធានារ៉ាប់រងថែទាំសុខភាពសម្រាប់ហានិភ័យការងារ ដូចជា:

- គ្រោះថ្នាក់ដែលកើតឡើងក្នុងម៉ោងធ្វើការ មិនថាដោយសារមូលហេតុអ្វីឡើយ
- គ្រោះថ្នាក់ដែលកើតឡើងក្នុងពេលកម្មករនិយោជិតធ្វើដំណើរដោយផ្ទាល់ទៅ និងមកពីកន្លែងធ្វើការ
- ជំងឺវិជ្ជាជីវៈដែលជាជំងឺកើតឡើងដោយសារការងារ

មុនពេលមានការបង្កើតរបបធានារ៉ាប់រងគ្រោះថ្នាក់ការងារនេះឡើង និយោជកគឺជាអ្នកទទួលខុសត្រូវដោយផ្ទាល់លើចំណាយសម្រាប់ការព្យាបាល និងលើការខាតបង់ប្រាក់ឈ្នួលដោយសារតែគ្រោះថ្នាក់ដែលពាក់ព័ន្ធនឹងការងារ។ ឥលូវនេះ កម្មករនិយោជិតដែលត្រូវការការព្យាបាលដោយសារតែហានិភ័យការងារអាចទទួលបានការថែទាំដោយឥតគិតថ្លៃនៅតាមមន្ទីរពេទ្យដែលទទួលស្គាល់ដោយ ប.ស.ស ឬទាមទារសំណងសម្រាប់ការចំណាយដែលមានសុពលភាពលើការព្យាបាលដែលផ្តល់ដោយមន្ទីរពេទ្យផ្សេងទៀត។

ប.ស.ស ក៏ផ្តល់ឱ្យកម្មករនិយោជិតនូវប្រាក់ឈ្នួលចំនួន ៧០% នៃប្រាក់ឈ្នួលខាតបង់របស់ពួកគេផងដែរនៅពេលដែលពួកគេមិនអាចធ្វើការងារបណ្តោះអាសន្នដោយសារតែហានិភ័យការងារ។[៨] នៅក្នុងករណីអសមត្ថភាពអចិន្ត្រៃយ៍ អត្ថប្រយោជន៍អាចមានការប្រែប្រួលអាស្រ័យទៅតាមកម្រិតធ្ងន់ធ្ងរនៃពិការភាព អាយុ និងប្រាក់ឈ្នួលរបស់កម្មករនិយោជិត។ នៅពេលដែលមានភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ អ្នកថែទាំកម្មករនិយោជិតក៏អាចទទួលបានអត្ថប្រយោជន៍ផងដែរ (ជាធម្មតាចំនួនពាក់កណ្តាលដែលកម្មករនិយោជិតមានសិទ្ធិទទួលបាន)។ ប្រសិនបើហានិភ័យការងារបង្កឱ្យស្លាប់ ប.ស.ស ជួយចេញថ្លៃរៀបចំពិធីបុណ្យសព និងផ្តល់អត្ថប្រយោជន៍ដល់គ្រួសាររបស់កម្មករនិយោជិត។[៩]



[៦] ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០០៩: ប្រកាសលេខ ១៣៣-០៩ ស្តីពីការកាត់បន្ថយអត្រាវិភាគទាន ប.ស.ស សម្រាប់វិស័យកាត់ដេរ (www.camfeba.com/)

[៧] ប.ស.ស ២០១០ (www.nssf.gov.kh/)

[៨] គិតមកត្រឹមខែមិនា ឆ្នាំ២០១០ នេះ ការគ្របដណ្តប់សម្រាប់ពិការភាពជាបណ្តោះអាសន្នគឺចាប់គិតពីថ្ងៃទី ៥ នៃការព្យាបាល ឬនៃការឈប់សម្រាក ដែលមានការបញ្ជាក់ពីគ្រូពេទ្យតទៅ។ ប៉ុន្តែ ការដាក់កម្រិតបែបនេះនឹងមានការផ្លាស់ប្តូរ។ និយោជកត្រូវរ៉ាប់រងការខាតបង់ប្រាក់ឈ្នួលចាប់ពីថ្ងៃទីមួយ តទៅដោយមិនគិតពីរយៈពេលនៃពិការភាពបណ្តោះអាសន្ន។

[៩] ប្រកាសលេខ ១០៩/០៨

## របបធានារ៉ាប់រងសុខភាព

ព័ត៌មានលម្អិតអំពីពេលវេលា និងអត្ថប្រយោជន៍នៃការធានារ៉ាប់រងលើការថែទាំសុខភាពរបស់រដ្ឋាភិបាលនៅមិនទាន់ត្រូវបានកំណត់នៅឡើយទេ។

ប៉ុន្តែ ក្នុងពេលជាមួយគ្នានេះដែរក្រុមស្រាវជ្រាវ និងផ្លាស់ប្តូរបច្ចេកវិទ្យា (GRET) និងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) កំពុងសាកល្បងរបបធានារ៉ាប់រងសុខភាពថ្មីបែបស្ម័គ្រចិត្តសម្រាប់កម្មករនិយោជិតដែលទទួលបានបៀវត្សរ៍នៅក្នុងឧស្សាហកម្មកាត់ដេរ។ គម្រោងធានារ៉ាប់រងសុខភាព (HIP) នឹងដាក់ឱ្យប្រើប្រាស់នូវការធានារ៉ាប់រងសុខភាពសង្គមបែបស្ម័គ្រចិត្តមួយដែលឆ្លើយតបទៅនឹងតម្រូវការរបស់កម្មករនិយោជិតតាមរយៈការធ្វើឱ្យកាន់តែប្រសើរនូវស្ថានភាពសុខភាព និងកាត់បន្ថយភាពងាយរងគ្រោះ និងការលំបាកនៅក្នុងករណីមានជំងឺ និងឆ្លើយតបទៅនឹងតម្រូវការរបស់និយោជកតាមរយៈការបង្កើនផលិតភាពរបស់កម្លាំងពលកម្មដែលមានសុខភាពល្អប្រសើរជាងមុន។

សម្រាប់រោងចក្រដែលបានចូលរួមការចំណាយលើការបង់វិភាគទាននៃការធានារ៉ាប់រងសុខភាពគឺប្រហែលជា ១,៦០ ដុល្លារក្នុងមួយខែ សម្រាប់កម្មករនិយោជិតដែលត្រូវបានធានារ៉ាប់រង។ ចំនួនទឹកប្រាក់នេះមិនបានរាប់បញ្ចូលលើការចំណាយផ្នែករដ្ឋបាលដែលត្រូវបានឧបត្ថម្ភធនដោយគំរោងនេះឡើយ។ ការទូទាត់នូវប្រាក់បុព្វលាភធានារ៉ាប់រងនេះ គឺជាការចំណាយដែលនិយោជក និងកម្មករនិយោជិតត្រូវចែករំលែកស្មើៗគ្នា។

បន្ទាប់ពីបានចុះឈ្មោះក្នុងកម្មវិធីនេះហើយ កម្មករនិយោជិតអាចទទួលបានសេវា ដូចជា៖

- ការថែទាំសុខភាពមុន និងក្រោយពេលសម្រាលក្នុងកម្រិតមូលដ្ឋាន
- ការថែទាំសុខភាពដែលមានការត្រួតពិនិត្យគុណភាព (ឱសថ បុគ្គលិកវេជ្ជសាស្ត្រដែលមានសមត្ថភាព) ដែលផ្តល់ដោយមូលដ្ឋានសុខាភិបាលសាធារណ៖
- ការចំណាយលើការថែទាំសុខភាពដែលពាក់ព័ន្ធ និងគ្រោះថ្នាក់ចរាចរណ៍ និងការទូទាត់សងប្រាក់ដែលបានចំណាយជាសរុបដើម្បីចំណាយលើការធ្វើដំណើរក្នុងករណីដែលមានការពន្យាក់ថាបានស្នាក់នៅមន្ទីរពេទ្យ

គំរោងធានារ៉ាប់រងសុខភាពគឺជាគំរោងសាកល្បងដែលនឹងទទួលបានចំណេះដឹង និងជំនាញបន្តិចម្តងៗនៅក្នុងការចំណាយជាមធ្យម និងភាពញឹកញាប់នៃការទាក់ទងនឹងផ្នែកថែទាំសុខភាពការគ្រប់គ្រងសមាជិកភាព ការរួមចំណែក និងការអះអាងបញ្ជាក់ ការគ្រប់គ្រង និងការត្រួតពិនិត្យនៃទំនាក់ទំនងជាមួយអ្នកផ្តល់ការថែទាំសុខភាព។ ហេតុនេះហើយ គំរោងនេះមានសារៈសំខាន់ ដែលសរុបសេចក្តីមកគំរោងនេះនឹងធ្វើលើការរៀបចំ និងការបង្កើតនូវរបបធានារ៉ាប់រងសុខភាពនាពេលអនាគតសម្រាប់កម្មករនិយោជិតក្នុងវិស័យឯកជន។

## របបសោធន

របបសោធនដែលគ្រោងនឹងអនុវត្តក្នុងឆ្នាំ ២០១២ នឹងផ្តល់អត្ថប្រយោជន៍ដល់សមាជិក ប.ស.ស នៅពេលដែលពួកគេចូលនិវត្តឬពិការមុនពេលចូលនិវត្ត។ អត្ថប្រយោជន៍រួមមានប្រាក់សោធននិងប្រាក់ឧបត្ថម្ភសម្រាប់ជរាភាព ប្រាក់សោធនសម្រាប់ការបាត់បង់សមត្ថភាពធ្វើការងារ និងអត្ថប្រយោជន៍សម្រាប់សមាជិកគ្រួសារដែលនៅរស់។ ដើម្បីអាចទទួលបានប្រាក់សោធនសម្រាប់ជរាភាពបានសមាជិក ប.ស.ស ត្រូវ៖

- មានអាយុតិចបំផុត ៥៥ ឆ្នាំ
- ជាសមាជិក ប.ស.ស យ៉ាងហោចណាស់រយៈពេល ២០ ឆ្នាំ
- បានបង់វិភាគទានដល់ ប.ស.ស យ៉ាងហោចណាស់ ៦០ ខែ នៅក្នុងរយៈពេល ១០ ឆ្នាំ មុនកាលបរិច្ឆេទមានសិទ្ធិទទួលបានអត្ថប្រយោជន៍[១០]

អត្ថប្រយោជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារមានសម្រាប់សមាជិករបស់ ប.ស.ស ដែលពិការមុនអាយុ ៥៥ ឆ្នាំ ប្រសិនបើពួកគេ៖

- ជាសមាជិករបស់ ប.ស.ស រយៈពេល ៥ ឆ្នាំ
- បានបង់វិភាគទានដល់ ប.ស.ស បាន ៦ ខែ នៃ ១២ ខែ មុនពេលមានពិការភាព

ទាំងកម្មករនិយោជិត ទាំងនិយោជកនឹងចូលរួមចំណែកគាំទ្រដល់មូលនិធិសម្រាប់របបសោធន។ ដូចគ្នានឹងរបបធានារ៉ាប់រងគ្រោះថ្នាក់ការងារដែរ របបសោធនគឺតម្រូវដោយច្បាប់ ហើយត្រូវអនុវត្តចំពោះគ្រប់និយោជិតទាំងអស់ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិរបស់ច្បាប់ស្តីពីការងារ។[១១]



[១០] ច្បាប់ស្តីពីរបបសន្តិសុខសង្គម (២០០២) មាត្រា ៧-១១

[១១] ច្បាប់ស្តីពីរបបសន្តិសុខសង្គម (២០០២); CAMFEBA ២០០៨: បទបង្ហាញអំពី ប.ស.ស (www.camfeba.com/docs/ National_Social_Security_Fund_xNSSFx_Workshop_Presentation_CAMFEBA.pdf)



## អ្វីដែលត្រូវធ្វើបន្តទៀត

ការអនុម័តច្បាប់ស្តីពីរបបសន្តិសុខសង្គម នៅក្នុងឆ្នាំ២០០២ ការបង្កើត ប.ស.ស នៅក្នុងឆ្នាំ២០០៧ និងការដាក់ឱ្យប្រើប្រាស់នូវរបបធានារ៉ាប់រងគ្រោះថ្នាក់ការងារនៅក្នុងឆ្នាំ២០០៨ ឆ្លុះបញ្ចាំងពីវឌ្ឍនភាពយ៉ាងសំខាន់ឆ្ពោះទៅការធានា ឱ្យបាននូវសន្តិសុខសេដ្ឋកិច្ច និងសុខុមាលភាពសង្គមសម្រាប់ប្រជាពលរដ្ឋកម្ពុជា។ ទោះបីជាប្រព័ន្ធរបបសន្តិសុខសង្គមប្រទេសកម្ពុជានៅមានភាពក្មេងខ្ចីក៏ដោយ ក៏ប៉ុន្តែមានមនុស្សជាច្រើនព្រមព្រៀងថាប្រទេសនេះកំពុងធ្វើដំណើរក្នុងទិសដៅមួយដែលត្រឹមត្រូវ។

ស្ថាប័នរដ្ឋាភិបាលកម្ពុជា អង្គការនិយោជក និងសហជីពបានប្តេជ្ញាចិត្តដើម្បីបង្កើតប្រព័ន្ធរបបសន្តិសុខសង្គមឱ្យបានទូលំទូលាយដែលផ្អែកលើតម្លាភាព ប្រសិទ្ធិភាព និងអភិបាលកិច្ចល្អ។

## តើគេនិយាយអ្វីខ្លះអំពី ប.ស.ស ?

**កញ្ញា វណ្ណី**

*ជាកម្មការនីកាត់ដេរដែលធ្លាប់ទទួលរងគ្រោះថ្នាក់ចរាចរណ៍ធ្ងន់ធ្ងរមួយកាលពីខែធ្នូ ឆ្នាំ២០០៨:*

*"ខ្ញុំសូមថ្លែងអំណរគុណអស់ពីដួងចិត្តចំពោះជំនួយដែលផ្តល់ដោយ ប.ស.ស។ បើគ្មានជំនួយនេះទេ ខ្ញុំប្រហែលជាស្លាប់បាត់ហើយ ដោយសារតែខ្ញុំគ្មានលុយដើម្បីបង់ឱ្យមន្ទីរពេទ្យ។ ខ្ញុំសង្ឃឹមថា ប.ស.ស នឹងបន្តសេវារបស់ខ្លួន និងជួយដល់មនុស្សជាច្រើននាក់ផ្សេងទៀតដែលមានស្ថានភាពស្រដៀងគ្នានេះដែរ។"*

**កញ្ញា អ៊ូ វួចលី**

*មន្ត្រីផ្នែកព័ត៌មាន និងច្បាប់របស់សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា* (CAMFEBA)

*"ដំបូងឡើយខ្ញុំតែងតែរិះគន់ ប.ស.ស យ៉ាងខ្លាំង។ ប៉ុន្តែ ខ្ញុំបានផ្លាស់ប្តូរគំនិតរបស់ខ្ញុំ ដោយសារតែខ្ញុំយល់ថា ប្រព័ន្ធនេះមានសក្តានុពលផ្តល់ផលប្រយោជន៍ដល់អ្នកដែលត្រូវការជំនួយ។ ខ្ញុំសង្ឃឹមថាពួកគេនឹងពង្រីកសេវាកម្មរបស់ខ្លួនដល់អាជីវកម្មខ្នាតតូចក្នុងពេលឆាប់ៗនេះ។"*

## ព័ត៌មានបន្ថែម:

- សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា (CAMFEBA) www.camfeba.com/
- CAMFEBA, សៀវភៅណែនាំអំពីបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់ហានិភ័យការងារនៅក្នុងប្រទេសកម្ពុជា (២០១០) (មានជាសៀវភៅ)
- បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) www.nssf.gov.kh/
- យុទ្ធនាការជាសកលរបស់អង្គការពលកម្មអន្តរជាតិស្តីពីរបបសន្តិសុខសង្គម និងការគ្របដណ្តប់សម្រាប់ទាំងអស់គ្នា www.ilo.org/public/english/protection/socsec/pol/campagne/index.htm
- គម្រោង HIP, info-hip@mekongnet.com

បោះពុម្ពផ្សាយនៅក្នុងខែមិថុនា ឆ្នាំ២០១០

**ព័ត៌មានបន្ថែម**

*រោងចក្រកាន់តែប្រសើរនៅកម្ពុជា*
ផ្ទះលេខ ៩, ផ្លូវលេខ ៣២២, បឹងកេងកង ១
ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ (+៨៥៥) ២៣ ២១២ ៨៤៧ ext 0
(+៨៥៥) ២៣ ២២០ ៣៦២
ទូរសារ (+៨៥៥) ២៣ ២១២ ៩០៣
អ៊ីម៉ែល betterfactories@ilo.org
គេហទំព័រ www.betterfactories.org/ilo